ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jan-2016, 10:26
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ១៤:០៥នាទី**

**សវនាការលើកទី៣៥៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms. Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី អ៊ីសាប៉ែល ឌុយរ៉ង់ដ៍
*(Ms. Isabelle DURAND)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[១៤:០៥:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយកាលពីថ្ងៃសុក្រ ទី១៥ ខែមករា ឆ្នាំ២០១៦ សហមេធាវីការពារក្តី នួន ជា បានដាក់ -- បាទហើយសវនាការ -- កាលពីថ្ងៃសុក្រ ទី១៥ ខែមករា ឆ្នាំ២០១៦ សហមេធាវីការពារក្តី នួន ជា បានដាក់សំណើសុំមួយ សុំឲ្យអង្គជំនុំជម្រះដកចេញវិញនូវសាក្សីមួយរូប ដែលមានរហស្សនាម 2-TCW-989 ពីបញ្ជីសាក្សីដែលត្រូវបានយល់ព្រមរួចហើយ ដែលអង្គជំនុំជម្រះ ដើម្បីផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០២។ ហើយនៅថ្ងៃដដែលនោះ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគី អំពីចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីនានា ប្រសិនបើមាន បន្ទាប់ពីការស្តាប់សក្ខីកម្មសាក្សី យូ វ៉ាន់។

ហើយអង្គជំនុំជម្រះ នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសធ្វើសារណាផ្ទាល់មាត់ តបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីការពារក្តីលោក នួន ជា លើសំណើដែលយើងបានប្រាប់អម្បាញ់មិញនេះ។

[១៤:០៦:៤១]

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតចំណុចខ្លីៗ ឆ្លើយតបទៅនឹងសំណើនេះ។ ជាបឋម គឺថាតាមពិត នេះគឺជា មិនមែនជាសាក្សីលោក នួន ជា សូមដកសាក្សីរូបនេះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះជាអ្នកជ្រើសរើស ហើយគឺជាការសម្រេចរបស់អង្គជំនុំជម្រះ ដោយសារខ្លួនជាអ្នកសម្រេចថា ត្រូវមានប្រយោជន៍ ដើម្បីស្តាប់គាត់ ឬមិនស្តាប់គាត់។ ទី២ យើងសូមបញ្ជាក់ជូនអង្គជំនុំជម្រះថា ការពិនិត្យ ឬក៏ការសួរដេញដោលតទល់ ដោយសហព្រះរាជអាជ្ញា ហើយនិងបណ្តឹងឧទ្ធរណ៍នៃសាក្សីនេះ គឺមានកម្រិតខ្លាំងណាស់ ដោយសារថា មានឯកសារច្រើនទាក់ទងនៅក្នុងកិច្ចដំណើរការនេះ ហើយសាក្សីហ្នឹង គឺថាយើងមិនអាចនឹងសួរដេញដោលតទល់បាននៅកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍។ ហើយសាក្សីនៅក្នុងបណ្តឹងសាទុក្ខ នៅក្នុងសវនាការបណ្តឹងសាទុក្ខហ្នឹង គឺភាគីមិនត្រូវបានអនុញ្ញាតឲ្យសួរគាត់ ទាក់ទងទៅនឹងការប្រើឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។ ហើយមានភាពផ្ទុយគ្នារវាងរឿងដែលគាត់ប្រាប់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយធៀបទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ

យើងមិនអាចមានឱកាសសួរតទល់ដេញដោលគាត់បានទេ។ ជាពិសេសបណ្តឹងសាទុក្ខនៅសាលាកំពូល។

ចំណុចទី២ ទាក់ទងទៅនឹងការវិនិច្ឆ័យលើភាពជឿជាក់បាននៃសាក្សី។ សាក្សីរូបនេះ គឺបានផ្តល់ភ័ស្តុតាងដែលផ្ទុយទៅនឹងតួអង្គនៃឯកសារនៃភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលជាការជឿជាក់ទៅលើនយោបាយរួមដែលប្រឆាំងនឹងទាហានលន់នល់ មន្ត្រីលន់នល់ ទូទាំងប្រទេស។

[១៤:០៨:៥២]

នៅក្នុងកាលៈទេសៈបែបនេះ គឺថា ដែលនឹងដាក់ចូលទៅជាភ័ស្តុតាង ជាសក្ខានុពលនោះ គឺថាមេធាវី នួន ជា ចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់នូវទម្ងន់ជាសារវន្តទៅលើសក្ខីកម្មរបស់សាក្សីរូបនេះ។ ខ្ញុំមិនប្រាកដថាតើអង្គជំនុំជម្រះអាចធ្វើបែបនេះបានដែរឬអត់ទេ ដោយមិនបានស្តាប់សាក្សីរូបនេះដោយផ្ទាល់ ដើម្បីវាយតម្លៃអំពីភាពជឿជាក់បាន ហើយប្រៀបធៀបទៅនឹងសាក្សីផ្សេងៗទៀត ដែលបានផ្តល់ភ័ស្តុតាងផ្ទុយពីគាត់។

អ្វីដែលយើងគិតឃើញ ឬក៏គិតទុកជាមុនបាននោះ គឺថាមូលដ្ឋានដែលមេធាវី នួន ជា អាចនឹងសម្រេច និងក្នុងការដកសំណើរបស់ខ្លួនវិញនៅពេលឥឡូវនេះ គឺថា គឺគ្រប់ករណីទាំងអស់ សាក្សីនេះគឺមិនមានភាពជឿជាក់បានទេ នៅក្នុងបណ្តឹងសាទុក្ខ នីតិវិធីបណ្តឹងសាទុក្ខ អាចនឹងនាំឲ្យមានផលអាក្រក់ដែលចេញពីសក្ខីកម្មរបស់សាក្សីនេះ។ អានេះ ខ្ញុំគិតពីគំនិតដែលពួកគាត់គិតទេ។

ចំណុចចុងក្រោយ មេធាវីការពារក្តីថា ការដាក់សំណើរបស់ខ្លួននោះ នឹងតម្រូវឲ្យមានការងារច្រើន ដោយភាគីដែលត្រូវធ្វើ។ ខ្ញុំមិនយល់ថា ទឡ្ហីករណ៍នេះខ្ញុំយល់ច្បាស់ទេ គឺថាគាត់អះអាងបែបនេះមិនត្រូវទេ ព្រោះយើងធ្វើការងារហ្នឹងគឺច្រើនរួចមកហើយលើសាក្សីនេះ គឺថាការនយោបាយប្រឆាំងទៅនឹងអតីតទាហាន លន់ នល់ ហើយនិងក្រុមមនុស្សផ្សេងទៀតដែលយើងបានពិភាក្សាដេញដោលនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ តាមអ្វីៗដែលខ្ញុំនិយាយខាងដើមនេះ យើងទុកការវិនិច្ឆ័យទៅលើអង្គជំនុំជម្រះក្នុងការសម្រេច ថាតើសក្ខីកម្មផ្ទាល់របស់សាក្សីនេះ ហើយបើប្រៀបធៀបទៅនឹងកំណត់ហេតុស្តាប់ចម្លើយ ហើយនិងសក្ខីកម្មចំពោះនីតិវិធីបណ្តឹងសាទុក្ខហ្នឹងត្រឹមត្រូវយ៉ាងដូចម្តេច ត្រូវសម្រេចម៉េច គឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសឡើងធ្វើសារណាតបទៅនឹងសំណើសុំរបស់លោកមេធាវីការពារក្តី

ក្រុមមេធាវីការពារក្ដីលោក នួន ជា។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីទេ លោកប្រធាន។ យើងសុំគាំទ្រទៅនឹងគោលជំហររបស់ព្រះរាជអាជ្ញា។ វាមិនមានជាសាក្សីដែលស្នើដោយមេធាវី នួន ជា ទេ។ គាត់ជាសាក្សីរបស់អង្គជំនុំជម្រះ ៗជាអ្នកសម្រេចថាតើខ្លួនគួរស្ដាប់ចម្លើយរបស់គាត់ ឬក៏អត់។ យើងគិតថា សំណើរបស់ នួន ជា ដែលដាក់ចំណងជើងហ្នឹងគឺមិនត្រឹមត្រូវទេ។ គាត់ស្នើសុំដកចេញពីបញ្ជីរបស់គាត់ពីព្រោះថា សាក្សីជាសាក្សីរបស់អង្គជំនុំជម្រះ។ ដូច្នេះ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាខ្លួនកោះហៅ ឬមិនកោះហៅ ដើម្បីស្វែងរកការពិត។ ក៏ប៉ុន្ដែទោះជាយ៉ាងណាក៏ដោយ យើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះទៅលើបញ្ហានេះ។ សូមអរគុណលោកប្រធាន។

[១៤:១២:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៀត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ថាតើមានចង់មានមតិយោបល់អ្វីដែរទេ ឬក៏ការធ្វើការកត់សម្គាល់អ្វីដែរទេ លើសំណើសុំរបស់សហមេធាវីការពារក្ដីលោក នួន ជា លើបញ្ហានេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏សុំលើកឡើងដោយខ្លី។ ខ្ញុំសូមឆ្លើយតបដោយផ្អែកទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមបញ្ជាក់ជូនថា នេះដោយសារតែឥទ្ធិពលនៃដីកាបំបែកនីតិវិធី។ ដូច្នេះយើងចាំបាច់ត្រូវតែមានសាក្សីដែលសំខាន់។ ហើយដំបូងសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីគាត់គិតថា សាក្សីហ្នឹងមិនសំខាន់ នៅពេលដែលមានការធ្វើសំណើដំបូងទៅតុលាការកំពូលនោះ។ ខ្ញុំកត់សម្គាល់ឃើញថា ភាគីទាំងអស់មានលទ្ធភាពក្នុងការសួរផ្ទាល់ សួរដេញដោលសាក្សីរូបនោះ។ ហើយថ្ងៃនេះខ្ញុំស្ដាប់ឮសហព្រះរាជអាជ្ញាអន្ដរជាតិលើកឡើងអំពីភាពជឿជាក់បាននៃសាក្សីរូបនេះ។ ខ្ញុំគិតថា វាដូចជាលឿនពេកក្នុងការធ្វើបែបនេះ។ ក៏ប៉ុន្ដែទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីលោក ខៀវ សំផន យើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។ ហើយយើងសូមបញ្ជាក់ជូនថា បញ្ហាដែលមាននៅក្នុងសំណុំរឿង០០២/០២ យើងនេះ គឺប្រធានបទហ្នឹង គឺវាមានសារៈសំខាន់។ កាលនុំងគឺនៅលើសំណុំរឿង០០២/០១ គួរតែស្ដាប់នៅក្នុងពេលនោះ។ ហើយឥឡូវ

នេះខ្ញុំមើលទៅឃើញដូចជាមិនមានប្រយោជន៍អីដែលត្រូវចំណាយទៅលើសាក្សីរូបហ្នឹងទេ ព្រោះថា យើងមានសាក្សីផ្សេងទៀតដែលអាចមកផ្តល់សក្ខីកម្មបានល្អជាងគាត់ ហើយពេលវេលារបស់អង្គជំនុំជម្រះក៏ខ្លីដែរ។ ដូច្នេះអង្គជំនុំជម្រះគួរតែថ្លឹងថ្លែងពេលវេលា ដើម្បីជ្រើសរើសយកសាក្សីណាដែលមានប្រយោជន៍ជាងនៅក្នុងសំណុំរឿងយើងនេះ។ យើងចង់ធ្វើយ៉ាងម៉េច ដើម្បីឲ្យការសួរដេញដោលហ្នឹង វាមានប្រសិទ្ធភាពនៅពេលក្រោយ។ សូមអរគុណលោកប្រធាន។

[១៤:១៤:៤៨]

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសធ្វើសារណាតបទៅនឹងមតិយោបល់របស់ -- នួន ជា លោកមេធាវីការពារក្តី នួន ជា បាទ តបទៅនឹងមតិយោបល់ ឬក៏សារណារបស់ភាគីដទៃទៀតដែលបានលើកឡើងពាក់ព័ន្ធសំណើរបស់ខ្លួន។

សូមអញ្ជើញ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដែលនឹងគិតថា មានការភ្ញាក់ផ្អើលដែលចេញពីមាត់របស់សហព្រះរាជអាជ្ញាបែបនេះទេ។ ខ្ញុំឆ្លើយតបពីប្រវត្តិដោយសង្ខេបថា លោកប្រធានបានជ្រាបហើយ គឺថាចម្លើយរបស់សាក្សីជាក់លាក់នេះ គឺពីមុននោះ គឺមុនពេលការសួរដេញដោល បិទការដេញដោលក្នុងរឿងក្តី០០២/០១។ ហើយយើងមិនបានកត់សម្គាល់ទេនៅពេលនោះ ប៉ុន្តែយើងបានឃើញ យល់ឃើញពីសារៈសំខាន់នៃឯកសារ បន្ទាប់ពីមានសាលក្រម ហើយបន្ទាប់ពីយើងចូលរួមក្នុងបណ្តឹងសាទុក្ខ។ ដោយសារមូលហេតុទាំងអស់នេះហើយ យើងគិតថាសារៈសំខាន់នេះហើយដែលថា យើងស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលស្តាប់សាក្សីរូបនេះ។ អង្គជំនុំជម្រះក៏អាចនឹងដឹង ចាំផងដែរថា នៅពេលដែលយើងនិយាយពីសវនាការលើត្រាំកក់ ក្រាំងតាចាន់ គឺខ្ញុំសួរសាក្សីគ្រប់ៗគ្នាទាំងអស់ ថាតើបុគ្គលម្នាក់នេះជាកម្មាភិបាលដែរឬទេ ហើយថាតើសាក្សីទាំងនោះអាចបញ្ជាក់ពីចំណុចសំខាន់ ពីអ្វីដែលសាក្សីនេះនិយាយដែលពីការប្រជុំដោយ តាម៉ុក ដោយគាត់និយាយថា មន្ត្រី លន់ នល់ ឬក៏ទាហាន លន់ នល់ ជាដើមហ្នឹង ដែលចាប់ពីស័ក្តិ៣ចុះទៅក្រោមទៅហ្នឹង មិនត្រូវប៉ះពាល់ គឺថាមិនមានអ្នកណាម្នាក់បញ្ជាក់ត្រឹមត្រូវទេ។ ដូច្នេះ ពេជ្រ ជឹម ដែលមកធ្វើសក្ខីកម្មក៏បានបញ្ជាក់ពីរឿងនេះដែរ ហើយសាក្សីនេះក៏ត្រូវបានអង្គជំនុំជម្រះសាលាកំពូលកោះអញ្ជើញគាត់។ យើងអត់មានឱកាសនឹងសួរសំណួរទាំងអស់ដែល

យើងចង់ទេ ហើយគាត់បញ្ជាក់នៅក្នុងចម្លើយពីដើមថា គាត់ពិតជាបានស្តាប់ឮសេចក្តីប្រកាសបែបនេះ របស់ តាម៉ុក។ អ៊ីចឹងហើយភាគី ក៏ដូចជាអង្គជំនុំជម្រះគាត់បញ្ជាក់ថា យើងមិនត្រូវការសាក្សីនេះទេ ដើម្បីកុំឲ្យខាតពេល ដើម្បីសួរសំណួរដដែល។ ប៉ុន្តែឥឡូវនេះ សវនាការដែលនិយាយពីមូលដ្ឋានសំខាន់ ដែលថា យើងត្រូវដកចេញ ដោយសារថាគាត់មិនមានអ្វីគួរឲ្យជឿជាក់។

[១៤:១៧:៤៤]

ដូច្នេះយើង -- បាទ បើសិនជាអង្គជំនុំជម្រះមានមូលដ្ឋានថា គួរឲ្យជឿជាក់ គួរឲ្យជឿបានទេ ដូច្នេះគឺថាអាចនឹងកោះអញ្ជើញបាន។ ប៉ុន្តែគាត់បញ្ជាក់នៅសាលាកំពូលថា នូវផ្នែកមួយដែលគាត់បញ្ជាក់ថា គាត់បញ្ជាក់កាលនោះថា មិនមានគោលនយោបាយបែបនោះទេ ដែលសហព្រះរាជអាជ្ញាបញ្ជាក់ថា ភ័ស្តុតាងរបស់គាត់វាផ្ទុយពីឯកសារទាំងឡាយរបស់សាក្សី របស់ផ្សេងនោះ ក៏មិនពិតដែរ។ ហើយឯកសារដែលសហព្រះរាជអាជ្ញាយោងទៅនោះ ដែលនិយាយពីឯកសារក្រាំងតាចាន់ ដែលនិយាយអំពីទាហាន លន់ នល់ នយោបាយពាក់ព័ន្ធនឹងទាហាន លន់ នល់ តែប៉ុណ្ណោះ នៅខែមីនា ឆ្នាំ១៩៧៧។ ហើយគាត់យោងទៅរកការប្រជុំ មិនមែននៅឆ្នាំ១៩៧៥ទេ គឺមុនឆ្នាំ១៩៧៥ទៅទៀត។

យើងឃើញថាសាក្សីនេះ គួរឲ្យជឿជាក់បាន យើងអាចបានសួរសំណួរទាំងអស់នោះហើយ ហើយយើងបានធ្វើបែបនោះ ដើម្បីជាអត្ថប្រយោជន៍ដល់ភាគីទាំងអស់ ដល់អង្គជំនុំជម្រះនោះផងដែរ។ ហើយខ្ញុំរីករាយក្នុងការដកសំណើរបស់ខ្ញុំវិញក៏បាន បើសិនជាអង្គជំនុំជម្រះសម្រេចបែបនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ដកសំណើរបស់ខ្លួនវិញ?

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែ-- បាទ អ៊ីចឹងគឺថាយើងមិនមានបញ្ហាអ្វីទេ សហព្រះរាជអាជ្ញាឆ្លើយផ្ទុយពីខ្ញុំ។

[១៤:១៩:០៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើដូច្នេះលោកដកសំណើរបស់លោកវិញ ឬក៏ទុក?

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាសំណួរត្រឹមត្រូវណាស់លោកស្រីចៅក្រម។ ទេ យើងមិនដកសំណើរបស់យើងខ្ញុំវិញទេ ជាសំណើ គឺថាគួរឲ្យជឿជាក់បានដ៏ល្អរបស់យើងខ្ញុំ។ ហើយសហព្រះរាជអាជ្ញានិយាយថា ជាសាក្សី

មួយដែលចាំបាច់ ប៉ុន្តែសំណើរបស់ខ្ញុំ ខ្ញុំពិនិត្យឃើញថា សាក្សីនេះមិនមានភាពពាក់ព័ន្ធទេ បានខ្ញុំស្នើពីខាងដើម។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប យើងមិនយល់ស្របទាល់តែសោះអំពីមេធាវីការពារក្ដីនិយាយថា មិនមានភាពជឿជាក់លើសាក្សី ហើយគាត់ថាដកសាក្សី។ បើគាត់ប្រើពាក្យថាៗគាត់គួរឲ្យជឿជាក់បាន ហេតុអីក៏ខ្លួនស្នើសុំដកសាក្សីនេះ? អ៊ីចឹងគឺថាអាចនឹងមានសាក្សីរាប់រយផ្ទុយ ធ្វើសក្ខីកម្មផ្ទុយពីសាក្សីបែបនេះ។ ហើយដូច្នេះគឺថាមិនប្រាកដថាគាត់មានការសួរដេញដោលហ្នឹងមានកម្រិតទេ។ វានឹងស្ថិតនៅក្នុងដៃរបស់លោក កូប៉េ ប៉ុន្តែខ្ញុំមិនឃើញថាហេតុអ្វីតុលាការត្រូវធ្វើវិនិច្ឆ័យភាពទស្សនៈផ្សេងៗ ទៅលើថាភាពជឿជាក់លើបានលើសាក្សីនោះ ដោយមិនស្ដាប់សាក្សីនោះទេ។

[១៤:២០:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រសិនបើអង្គជំនុំជម្រះពិនិត្យមើលចម្លើយ១០០នាក់ហើយ ហើយបើចន្លោះម្នាក់នេះគឺថាអាចនឹងជាការអាចឲ្យអង្គជំនុំជម្រះវិនិច្ឆ័យថាត្រូវកោះ ឬមិនកោះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយកិច្ចពិភាក្សាលើសំណើសុំរបស់សហមេធាវីការពារក្ដីលោក នួន ជា បានចប់ហើយ។ ហើយអង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ដែលបានលើកឡើងនូវសារណាផ្ទាល់មាត់របស់ខ្លួនពាក់ព័ន្ធនឹងសំណើសុំរបស់សហមេធាវីការពារក្ដី នួន ជា ដែលបានសុំដកសាក្សីមួយរូប ដែលមានរហស្សនាម 2-TCW-989 ចេញពីបញ្ជីសាក្សីសម្រាប់សវនាការសំណុំរឿង ០០២/០២ ដែលជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះយកទៅពិចារណា ពិភាក្សាសម្រេចលើសំណើសុំនេះ ដើម្បីចេញសេចក្ដីសម្រេចក្នុងរយៈពេលឆាប់ៗខាងមុខនេះ។

បាទ ឥឡូវនេះដល់ពេលទំនងត្រូវបន្តស្ដាប់សក្ខីកម្មសាក្សីមួយរូបទៀត គឺដែលយើងត្រូវស្ដាប់នោះគឺសាក្សីដែលមានរហស្សនាម 2-TCW-938 ជាអសាធារណៈ។ ហេតុដូច្នេះអង្គជំនុំជម្រះបង្គាប់ឲ្យបុគ្គលិកនៃផ្នែកសោតទស្សន៍ផ្ដាច់ប្រព័ន្ធផ្សព្វផ្សាយសំឡេង និងរូបភាពនៃកិច្ចដំណើរការសវនាការទៅសាលសវនាការធំសម្រាប់សាធារណជន ទៅបន្ទប់ផ្សព្វផ្សាយសម្រាប់សារព័ត៌មាន និងទៅបុគ្គលិក អ.វ.ត.ក ផ្សេងទៀត តាមរយៈការផ្សាយតែវីឌីអូសម្រាប់ផ្ទៃក្នុង។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-938 និង លោកមេធាវី ម៉ម រិទ្ធា ចូលមកកាន់ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ៕

*(សវនាការសម្រាកនៅម៉ោង១៤:២២នាទី)*